# ច្បាប់ស្តីពីខ្សែច្រវាក់ផ្គត់ផ្គង់អាល្លឺម៉ង់ថ្មី អាចមានផលប៉ះពាល់ដល់ក្រុមហ៊ុនផ្គត់ផ្គង់នៅកម្ពុជា

ថ្ងៃទី17 ខែមករា ឆ្នាំ2023

ច្បាប់អាល្លឺម៉ង់ថ្មីមួយ តម្រូវឱ្យបណ្តាក្រុមហ៊ុនទាំងឡាយធ្វើការពិនិត្យផ្ទៀងផ្ទាត់ភាពត្រឹមត្រូវផ្នែកសិទ្ធិមនុស្ស និងបរិស្ថាននៅក្នុងខ្សែច្រវាក់ផ្គត់ផ្គង់របស់ខ្លួនឱ្យបានសមស្រប។ ច្បាប់ស្តីពីកាតព្វកិច្ចពិនិត្យផ្ទៀងផ្ទាត់ត្រឹមត្រូវរបស់ក្រុមហ៊ុនក្នុងខ្សែច្រវាក់ផ្គត់ផ្គង់ (Lieferkettensorgfaltsplichtengesetz, LkSG) អនុវត្តចាប់ពីថ្ងៃទី01 ខែមករា ឆ្នាំ2023 ចំពោះក្រុមហ៊ុនអាល្លឺម៉ង់ និងអាចនឹងមានផលប៉ះពាល់ដល់ធុរកិច្ចនៅកម្ពុជា។

ច្បាប់ថ្មីនេះ ដាក់បញ្ចូលកាតព្វកិច្ចពិនិត្យផ្ទៀងផ្ទាត់ត្រឹមត្រូវចំពោះបណ្តាក្រុមហ៊ុន ដូចជា ការបង្កើតប្រព័ន្ធគ្រប់គ្រងហានិភ័យ ការវិភាគហានិភ័យជាទៀងទាត់ ការចាត់វិធានការទប់ស្កាត់ និងកែតម្រូវ ការបង្កើតនីតិវិធីប្តឹងតវ៉ា និងការរាយការណ៍អំពីវិធានការដែលអនុវត្ត។ កាតព្វកិច្ចនេះអនុវត្តចំពោះប្រតិបត្តិការផ្ទាល់ខ្លួន ក្រុមហ៊ុនផ្គត់ផ្គង់ផ្ទាល់ ហើយក្នុងករណីសង្ស័យ ក៏អនុវត្តចំពោះខ្សែច្រវាក់ផ្គត់ផ្គង់ផ្សេងទៀតផងដែរ។ លក្ខខណ្ឌតម្រូវទាំងនេះអនុវត្តចំពោះបណ្តាក្រុមហ៊ុននៅអាល្លឺម៉ង់ដែលមានកម្មករនិយោជិតយ៉ាងតិច 3,000 នាក់ ចាប់ពីថ្ងៃទី01 ខែមករា ឆ្នាំ2023 និងចំពោះបណ្តាលក្រុមហ៊ុនដែល មានកម្មករនិយោជិតយ៉ាងតិច 1,000 នាក់គិតចាប់ពីថ្ងៃទី01 ខែមករា ឆ្នាំ2024 ដែលប៉ះពាល់ដល់ក្រុមហ៊ុនសរុបប្រមាណពី 300 ទៅ 700 នៅត្រឹមឆ្នាំ2023 និងឆ្នាំ2024។

ច្បាប់ថ្មីនេះ គឺជាលើកទីមួយហើយ ដែលផ្តល់មូលដ្ឋានផ្លូវច្បាប់ក្នុងការកំណត់ឱ្យក្រុមហ៊ុនអាល្លឺម៉ង់ទទួលខុសត្រូវលើការគោរពសិទ្ធិមនុស្ស និងការពារបរិស្ថានក្នុងខ្សែច្រវាក់ផ្គត់ផ្គង់សកលនោះ។ តាមរយៈគំនិតផ្តួចផ្តើមថ្មីនេះ រដ្ឋាភិបាលអាល្លឺម៉ង់មានគោលដៅការពារសិទ្ធិប្រជាជនជាសកល ដែលផលិតផលិតផលសម្រាប់ផ្គត់ផ្គង់ទីផ្សារអាល្លឺម៉ង់ កាត់បន្ថយហានិភ័យចំពោះប្រជាជន និងបរិស្ថាន

តាមរយៈ ប្រតិបត្តិការធុរកិច្ច និងលើកកម្ពស់លទ្ធភាពស្វែងរកដំណោះស្រាយកាន់តែប្រសើរសម្រាប់ភាគីរងគ្រោះ។

តាមរយៈច្បាប់ចងកាតព្វកិច្ចផ្លូវច្បាប់នេះ អ្នកទិញអាល្លឺម៉ង់ទំនងជាអាចធ្វើការទាមទារឱ្យមានប្រព័ន្ធគ្រប់គ្រប់និរន្តរភាពកាន់តែប្រសើរពីក្រុមហ៊ុនផ្គត់ផ្គង់ដើម្បីបំពេញតាមលក្ខខណ្ឌតម្រូវរបស់ខ្លួន។ លក្ខខណ្ឌនេះ រួមមាន ការបង្កើតយន្តការប្តឹងតវ៉ានៅរោងចក្រ ការផ្តល់ទិន្នន័យពាក់ព័ន្ធ និងការផ្តល់លក្ខខណ្ឌដល់កម្រិតខ្សែច្រវាក់ផ្គត់ផ្គង់ខាងក្រោមៗ។ ដោយមានរបាយនាំចេញចំនួន 4.8% នៅឆ្នាំ2022 (1.08 ប៊ីលានដុល្លារអាមេរិក) អាល្លឺម៉ង់គឺជាប្រទេសគោលដៅសម្រាប់ការនាំចេញបំផុតលំដាប់ទីប្រាំមួយសម្រាប់កម្ពុជា បន្ទាប់ពីសហរដ្ឋអាមេរិក វៀតណាម ចិន ជប៉ុន និងកាណាដា។ ហេតុដូច្នេះ ច្បាប់ថ្មីនេះនឹងប៉ះពាល់ដោយផ្ទាល់ដល់អតិថិជនសំខាន់ៗរបស់ក្រុមហ៊ុនផ្គត់ផ្គង់កម្ពុជាជាច្រើន ហើយដូច្នេះក្រុមហ៊ុនផ្គត់ផ្គង់អាចនឹងផ្ទេរផលប៉ះពាល់ទាំងនេះមកដល់ក្រុមហ៊ុនផ្គត់ផ្គង់នៅកម្ពុជាតាមរយៈការបង្កើនតម្រូវការពីអ្នកទិញរបស់ខ្លួន។

ទោះបីជានិរន្តរភាពមិនមែនជាប្រធានបទថ្មីថ្មោងទាំងស្រុងសម្រាប់ក្រុមហ៊ុនផ្គត់ផ្គង់កម្ពុជា ហើយថាកម្ពុជា សម្រេចបាននូវវឌ្ឍនភាពនិរន្តរភាពគួរឱ្យកត់សម្គាល់ផ្នែកអនុលោមភាពសង្គមជាច្រើនទសវត្សរ៍កន្លងមកនេះក្តី ក៏ដូចជា កម្មវិធីរោងចក្រកាន់តែប្រសើរនៅកម្ពុជា (BFC) របស់ ILO-IFC - បញ្ហាប្រឈមនៅតែមានពាក់ព័ន្ធនឹងការពិនិត្យផ្ទៀងផ្ទាត់ភាពត្រឹមត្រូវ ឧទាហរណ៍ ពាក់ព័ន្ធនឹងសេរីភាពសមាគម ការបៀតបៀនផ្លូវភេទ និងការរើសអើង ព្រមទាំងសុខភាព និងសុវត្ថិភាពការងារផងដែរ។ ក្រៅពីបញ្ហាសង្គម និងសិទ្ធិមនុស្សទាំងនេះ ក៏មានការផ្តោតជាសំខាន់ថែមទៀតលើហានិភ័យបរិស្ថានដូចជា ការបំភាយឧស្ម័នផ្ទះកញ្ចក់ និងសំណល់ផងដែរ។ ច្បាប់អាល្លឺម៉ង់ថ្មី និងច្បាប់ដែលមានស្រាប់ និងច្បាប់ថ្មីនាពេលអនាគតនៅក្នុងប្រទេសផ្សេងៗ ដូចជា សហរដ្ឋអាមេរិក (ច្បាប់ស្តីពីការទប់ស្កាត់ការងារដោយបង្ខំជនជាតិអ៊ុយហ្គើរ ច្បាប់ស្តីពីតម្លាភាពខ្សែច្រវាក់ផ្គត់ផ្គង់រដ្ឋកាលីហ្វ័រញ៉ា ឆ្នាំ2012) ជប៉ុន (គោលការណ៍ណែនាំស្តីពីការពិនិត្យផ្ទៀងផ្ទាត់ភាពត្រឹមត្រូវផ្នែកសិទ្ធិមនុស្ស) ន័រវេ (ច្បាប់ស្តីពីតម្លាភាពន័រវេ) ឬសហភាពអឺរ៉ុប (សេចក្តីណែនាំស្តីពីការពិនិត្យផ្ទៀងផ្ទាត់ភាពត្រឹមត្រូវនិរន្តរភាពក្រុមហ៊ុន) បន្តបង្កើនផលប៉ះពាល់ចំពោះខ្សែច្រវាក់ផ្គត់ផ្គង់ជាសកល ដោយសារតែ ច្បាប់នោះមាន

ចែងអំពីលក្ខខណ្ឌតម្រូវចងភ្ជាប់កាតព្វកិច្ចផ្លូវច្បាប់សម្រាប់ប្រទេសនាំចូលកាន់តែច្រើនឡើង និងមានវិធីសាស្រ្តកាន់តែមានតម្លាភាព និងលក្ខណៈជាប្រព័ន្ធក្នុងការវាយតម្លៃហានិភ័យសង្គម និងបរិស្ថាន។ ហេតុដូច្នេះ មានការរំពឹងទុកថា នឹងមានទំនាក់ទំនងយ៉ាងជិតស្និតដែលផ្អែកតាមគំរូទំនួលខុសត្រូវរួម និងតម្លាភាពទិន្នន័យកាន់តែប្រសើររវាងអ្នកទិញ និងក្រុមហ៊ុនផ្គត់ផ្គង់។

ការអនុវត្តច្បាប់ស្តីពីខ្សែច្រវាក់ផ្គត់ផ្គង់នឹងត្រូវពិនិត្យតាមដានដោយការិយាល័យសហព័ន្ធសម្រាប់កិច្ចការសេដ្ឋកិច្ច និងការត្រួតពិនិត្យការនាំចេញ (BAFA) ដែលមានសិទ្ធិធ្វើសវនកម្មលើក្រុមហ៊ុន ស៊ើបអង្កេតលើការរំលោភបំពាន និងដាក់ពិន័យរដ្ឋបាល។ ដើម្បីជួយក្រុមហ៊ុនបំពេញតាមលក្ខខណ្ឌតម្រូវស្តីពីការពិនិត្យផ្ទៀងផ្ទាត់ភាពត្រឹមត្រូវឱ្យបានគ្រប់គ្រាន់ BAFA បានបោះពុម្ពផ្សាយឯកសារណែនាំ ជាប្រចាំ។

ក្រៅពីនេះ អង្គការសហប្រតិបត្តិការអន្តរជាតិអាល្លឺម៉ង់ (អង្គការ GIZ) និងសភាពាណិជ្ជកម្មអឺរ៉ុបនៅកម្ពុជា (EuroCham) មានបេសកកម្មគាំទ្រដោយផ្ទាល់ដល់ក្រុមហ៊ុនផ្គត់ផ្គង់នៅកម្ពុជាក្នុងការរៀបចំខ្លួនដើម្បីបំពេញតាមលក្ខខណ្ឌតម្រូវនៃការពិនិត្យផ្ទៀងផ្ទាត់ភាពត្រឹមត្រូវថ្មី ដែលដាក់ចេញដោយការផ្លាស់ប្តូរច្បាប់ តាមរយៈការបង្កើតមជ្ឈមណ្ឌលធុរកិច្ចដែលមានទំនួលខុសត្រូវ (RBH)។ មជ្ឈមណ្ឌល RBH គឺជាកន្លែងផ្តល់សេវាដែលផ្តល់ការសម្រួល និងផ្តល់ព័ត៌មានដោយឥតគិតថ្លៃ ក៏ដូចជាសេវាពិគ្រោះយោបល់អំពីនិរន្តរភាព និងការគ្រប់គ្រងហានិភ័យនៃការពិនិត្យផ្ទៀងផ្ទាត់ភាពត្រឹមត្រូវ ហើយក៏ជាផ្នែកមួយនៃ បណ្តាញជាសកលរបស់មជ្ឈមណ្ឌល RBH ផងដែរ ដោយសារអង្គការ GIZ កំពុងលើកកម្ពស់ការអនុវត្តពិនិត្យផ្ទៀងផ្ទាត់ភាពត្រឹមត្រូវសិទ្ធិមនុស្ស និងបរិស្ថានក្នុងបណ្តាប្រទេសផ្សេងទៀត រួមមាន វៀតណាម បង់ក្លាដែស និងស៊ែប៊ី ដើម្បីគាំទ្រដល់រោងចក្រក្នុងស្រុកលើប្រធានបទដែលពាក់ព័ន្ធនឹងនិរន្តរភាព និងការពិនិត្យផ្ទៀងផ្ទាត់ភាពត្រឹមត្រូវ។

លោកអ្នកអាចរកបានព័ត៌មានបន្ថែមអំពីមជ្ឈមណ្ឌល RBH និងការពិនិត្យផ្ទៀងផ្ទាត់ភាពត្រឹមត្រូវ រួមទាំងការបកប្រែអំពីច្បាប់ស្តីពីកាតព្វកិច្ចស្តីពីភាពត្រឹមត្រូវក្រុមហ៊ុនក្នុងខ្សែច្រវាក់ផ្គត់ផ្គង់ជាភាសាខ្មែរ និងអង់គ្លេស សូមចូលទៅកាន់វែបសាយត៍ RBH។

## <u>អំពីអង្គការសហប្រតិបត្តិការអន្តរជាតិអាល្លឺម៉ង់ (អង្គការ GIZ)</u>

អង្គការសហប្រតិបត្តិការអន្តរជាតិអាល្លឺម៉ង់ (អង្គការ GIZ) គឺជាអង្គការផ្តល់ សេវាផ្នែក កិច្ចសហប្រតិបត្តិការអន្តរជាតិឈានគេមុខមួយ។ ក្នុងនាមជាសហគ្រាសសហព័ន្ធ យើងគាំទ្រដល់ក្រសួងកិច្ចសហប្រតិបត្តិ និងអភិវឌ្ឍន៍សេដ្ឋកិច្ច (BMZ) សហព័ន្ធអាល្លឺម៉ង់ដើម្បីសម្រេច គោលបំណងរបស់ខ្លួនក្នុងផ្នែកកិច្ចសហប្រតិបត្តិការអន្តរជាតិសម្រាប់ការអភិវឌ្ឍដោយចីរភាព។ យើងក៏ចូលរួមក្នុងការងារអប់រំជាលក្ខណៈអន្តរជាតិនៅជុំវិញពិភពលោកផងដែរ។ គម្រោងរបស់អង្គការ GIZ ដែលមានឈ្មោះថា "ការជំរុញ និងលើកកម្ពស់ធុរកិច្ចដោយចីរភាព និងការអនុវត្តឧស្សាហកម្មដោយមានទំនួលខុសត្រូវក្នុងឧស្សាហកម្មសម្លៀកបំពាក់" (FABRIC) នៅកម្ពុជា នឹងលើកឡើងអំពីចីរភាពក្នុងឧស្សាហកម្មវាយនភណ្ឌ និងកាត់ដេរផ្នែកសង្គម សេដ្ឋកិច្ច និងបរិស្ថាន ដោយមានវិធានការគ្រប់ជ្រុងជ្រោយបន្ថែមទៀតឱ្យវិស័យឯកជនចូលរួមក្នុងសកម្មភាពគម្រោងនេះ។ គម្រោងក៏កំពុងធ្វើការងារក្នុងប្រទេសបង់ក្លាដេស កម្ពុជា មីយ៉ាន់ម៉ា ប៉ាគីស្ថាន វៀតណាម និងសហការជាមួយតួអង្គនានានៅក្នុងប្រទេសចិនដោយគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងរបស់តំណាងធុរកិច្ច ស្ថាប័នរដ្ឋាភិបាល សង្គមស៊ីវិល និងសហជីពការងារដើម្បីកសាងឧស្សាហកម្មមួយនេះដែលផ្តល់ការងារមានគុណភាព ការពារបរិស្ថាន និងចូលរួមចំណែកដល់កំណើនសេដ្ឋកិច្ច។

សូមទំនាក់ទំនង៖

លោកស្រី Kristin Sommer មន្ត្រីសម្របសម្រួលបរិស្ថាន និងពិនិត្យផ្ទៀងផ្ទាត់ភាពត្រឹមត្រូវ តាមរយៈ អ៊ីមែល៖ kristin.sommer@giz.de

## អំពីសភាពាណិជ្ជកម្មអឺរ៉ុបនៅកម្ពុជា

**សភាពាណិជ្ជកម្មអឺរ៉ុបនៅកម្ពុជា** (EuroCham Cambodia) ត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ2011 ដោយសមាគមធុរកិច្ចបារាំង អាល្លឺម៉ង់ និងអង់គ្លេសនៅកម្ពុជាដើម្បីបំពេញមុខងារសភាផ្លូវការនៃសហគមន៍ធុរកិច្ចអឺរ៉ុបនៅព្រះរាជាណាចក្រកម្ពុជា។ ចាប់តាំងពីពេលនោះមក សមាជិកសភាពាណិជ្ជកម្មអឺរ៉ុបបានកើនចំនួនដល់ជាង 300 និង 5 គណៈកម្មាធិការ ដែលមានប្រទេសអឺរ៉ុបចំនួន 11។ **សភាពាណិជ្ជកម្ម**

**អឺរ៉ុបនៅកម្ពុជា** មានសកម្មភាពស្នូលលើកកម្ពស់ គាំទ្រ និងតំណាងឱ្យសមាជិករបស់ខ្លួន និងផលប្រយោជន៍ធុរកិច្ចអឺរ៉ុបដោយសហការជាមួយរាជរដ្ឋាភិបាលកម្ពុជាដោយមានគោលបំណងធ្វើឱ្យដំណើរការធុរកិច្ច និងបរិយាកាសវិនិយោគកាន់តែប្រសិទ្ធភាព និងទទួលបានផ្លែផ្កាសម្រាប់ទាំងអស់គ្នា។

សកម្មភាពសំខាន់ៗរបស់សភាពាណិជ្ជកម្មអឺរ៉ុបមានដូចខាងក្រោម

- ពិគ្រោះយោបល់ និងតស៊ូមតិចំពោះបញ្ហាសំខាន់ៗដែលមានទាក់ទងនឹងការធ្វើធុរកិច្ចនៅកម្ពុជា។
- ជំរុញឱ្យមានការវិនិយោគមកប្រទេសកម្ពុជា។
- ធ្វើការកែលម្អការទទួលបានធុរកិច្ចអឺរ៉ុបមកទីផ្សារកម្ពុជា និងពីទីផ្សារកម្ពុជាទៅទីផ្សារអឺរ៉ុប និងសម្របសម្រួលធុរកិច្ចរវាងសហគ្រាសខ្នាតតូច និងមធ្យមកម្ពុជា និងរដ្ឋជាសមាជិកអឺរ៉ុប។
- ផ្តល់សេវាទាក់ទងនឹងសេដ្ឋកិច្ច ច្បាប់ បច្ចេកទេស ហិរញ្ញវត្ថុ ទីផ្សារ និងបញ្ហាផ្សេងទៀតនៅអឺរ៉ុប និងកម្ពុជា និងព័ត៌មានជាក់លាក់អំពីឧស្សាហកម្មដល់វិនិយោគិន។
- លើកកម្ពស់អត្តសញ្ញាណធុរកិច្ចអឺរ៉ុបកាន់តែរឹងមាំជាមួយសហគមន៍ធុរកិច្ចកម្ពុជា។
- សហការជាមួយភាគីពាក់ព័ន្ធកម្ពុជាក្នុងការគាំទ្រកំណើនសេដ្ឋកិច្ចកម្ពុជាប្រកបដោយបរិយាបន្ន និងនិរន្តភាព។

សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនង៖

លោក Brian Badzmierowski មន្ត្រីជាន់ខ្ពស់ផ្នែកទំនាក់ទំនង

អ៊ីមែល៖ Pr.officer@eurocham-cambodia.org